ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០១៣/២១ ក.ប/ស.ជ.ណ.ម.ហ

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ ឬនាយកសហគ្រាស រោងចក្រ ក្រុមហ៊ុន ដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់ស្តីពីការងារ ដោយសារស្ថានភាពឆ្នាំ២០២១នេះ មានបញ្ហាជម្ងឺឆ្លងកូវីដ-១៩ នៅលើពិភពលោក និងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ធ្វើឱ្យជនបរទេសដែលធ្លាប់មានបណ្ណ/សៀវភៅការងារជនបរទេសឆ្នាំ២០២០ មួយចំនួនធំ មិនទាន់បានត្រឡប់ពីប្រទេសកំណើត ដើម្បីបំពេញការងាររបស់ពួកគាត់នៅឡើយ។

ក្រសួងសូមជូនដំណឹងដល់ម្ចាស់ ឬនាយកសហគ្រាស រោងចក្រ ក្រុមហ៊ុនទាំងអស់ ឱ្យបានជ្រាបថា ការស្នើសុំពន្យារសុពលភាពបណ្ណ/សៀវភៅការងារជនបរទេសឆ្នាំ២០២១ ត្រូវបានពន្យារពេលដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ ដោយមិនតម្រូវឱ្យធ្វើការផាកពិន័យសម្រាប់ជនបរទេស ដែលធ្លាប់មានបណ្ណ/សៀវភៅការងារជនបរទេសឆ្នាំ២០២០ឡើយ។ ចំពោះជនបរទេសដែលចូលថ្មីមកធ្វើការ ឬប្រកបអាជីវកម្ម នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញឯកសារឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស រោងចក្រ ក្រុមហ៊ុន និងជនបរទេសទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយប្រសិទ្ធភាព។

ថ្ងៃ សុក្រ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២១
រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានការងារ គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៥